ទើបកើតឡើង ។ មានវារៈ ៣ ។ ធម៌ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ដោយអារម្មណប្បច្ច័យ គឺ (បុគ្គល) នូវទាន ។បេ។ ចេញ អំពីឈាន ហើយពិចារណា នូវឈាន ត្រេកអរ រីករាយពេក: ប្រារព្ធ នូវកុសលនោះ ... ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ច: ... ទោមនស្ស កើតឡើង ពួកព្រះអរិយ: ពិចារណា នូវគោត្រភូ ពិចារណា នូវវោ-ទាន នូវពួកកិលេស ដែលលះបង់ហើយ ... នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ... នូវពួកកិលេស ដែលសន្សំហើយ ក្នុងកាលមុន ... នូវចក្ខុ ... នូវវត្ថុ ... ។ សេចក្ដីបំប្រួញ ។ ជាបច្ច័យ នៃការពិចារណា នូវអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ ។ សេចក្ដីបំប្រួញ ។ វារៈទាំង ២ ក្រៅនេះ ដូចគ្នានឹងឧបាទានទុកៈដែរ ។ ធម៌ ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទានក្ដី ធម៌ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទានក្ដី ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អធិបតិធម៌ ខាងក្រោម មានវារៈ ៣ ដូចឧបាទានទុកៈដែរ ។

[១៧១] ឧបាទានិយោ ចេវ នោ ច ឧបាទានោ ធម្មោ ឧបាទានិយស្ស ចេវ នោ ច ឧបាទានស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ ទានំ ។ បេ ។ ឈានា វុដ្ឋហិត្វា ឈានំ គរុំ កត្វា បច្ចវេក្ខតិ អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ . . . ទិដ្ឋិ ឧប្បជ្ជតិ ។ បេ ។ សេក្ខា គោត្រភុំ គរុំ កត្វា . . . វោទានំ . . . មគ្គំ . . . ផលំ . . . ឧបាទានិយេ ចេវ នោ ច ឧបាទានេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ។ បេ ។ ឧបាទានិយា ចេវ នោ ច ឧបាទានា ខន្ធា ឧប្បជ្ជន្តិ ។ សហជាតាធិបតិ ឧបាទានិយោ ចេវ នោ ច ឧបាទានោ អធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ អវសេសា ទ្វេបិ អារម្មណាធិបតិបិ សហជាតាធិបតិបិ ឧបាទានទុកសទិសា ។ យត្ថ អធិបតិបិ តីណិ ឧបាទានទុកសទិសា សព្វេ បច្ចយា ឧបាទានទុកសទិសា ឧបាទានិយេ លោកុត្តរំ នត្ថិ បច្ចនីយម្បិ វិត្ថារេ ទ្វេ គណនាបិ ឧបាទានទុកសទិសា ។

ឧបាទានុបាទានិយទុកំ និដ្ឋិតំ ។

ឧបាទានឧបាទានិយទុកៈ បញ្ហាវារៈ

(១៧១) ធម៌ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ (បុគ្គល) នូវទាន ។បេ។ ចេញ អំពីឈាន ធ្វើ នូវឈាន ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈ ធ្វើ នូវកុសលនោះ ឲ្យជាទីគោរព. . . ទិដ្ឋិ កើតឡើង ។បេ។ ពួកសេក្ខបុគ្គល ធ្វើ នូវគោត្រភូ ឲ្យជាទីគោរព. . . នូវវោទាន . . . នូវចក្ខុ . . . នូវវត្ថុ . . . ធ្វើ នូវពួកខន្ធ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន ឲ្យជាទីគោរព ត្រេកអរ រីករាយ រាគៈ ធ្វើ នូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ ។បេ។ ពួកខន្ធ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន កើតឡើង ។ ឯសហជាតាធិបតិ គឺ អធិបតិធម៌ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ បច្ច័យទាំង ២ ដ៏សេសក្តី អារម្មណាធិបតិក្តី សហជាតាធិបតិក្តី ដូចឧបាទានទុកៈដែរ ។ ឯការត និងអធិបតិ មានវារៈ ៣ ដូចឧបាទានទុកៈដែរ បច្ច័យទាំងអស់ ដូចឧបាទានទុកៈដែរ ឯលោកុត្តរៈ ក្នុងឧបាទានិយៈ មិនមានទេ បច្ចនីយៈក្តី ការរាប់ទាំង ២ យ៉ាង ក្រៅនេះក្តី ដូចឧបាទានទុកៈដែរ ។

ចប់ ឧបាទានឧបាទានិយទុកៈ ។

# ឧបាទានុបាទានសម្បយុត្តទុកំ

## បដិច្ចវារោ

(១៧២) ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច ធម្មំ បដិច្ច ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ទិដ្ឋុបាទានំ បដិច្ច កាមុបាទានំ ។ ចក្កំ កាតព្វំ ។ ឧបាទានញ្ចេវឧបាទានសម្បយុត្តញ្ច ធម្មំ បដិច្ច ឧបាទានសម្បយុត្តោ ចេវ នោ ច ឧបាទានោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧបាទានេ បដិច្ច សម្បយុត្តកា ខន្ធា ។ ឧបាទានញ្ចេវ ឧបាទានសម្បយុត្តញ្ច ធម្មំ បដិច្ច ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ ច ឧបាទានសម្បយុត្តោ ចេវ នោ ច ឧបាទានោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ទិដ្ឋុបាទានំ បដិច្ច កាមុបាទានំ សម្បយុត្តកា ច ខន្ធា ។ ចក្កំ ។ ឧបាទានសម្បយុត្តញ្ចេវ ។ សង្ខិត្តំ ។ អាមសនំ នានាករណំ ឧបាទានទុកសទិសំ នវ បញ្ហា រូបំ នត្ថិ ឯវំ សព្វេបិ វារា វិត្ថារេតព្វា អរូបំយេវ ។

# ឧបាទានឧបាទានសម្បយុត្តទុកៈ

## បដិច្ចវារៈ

(១៧២) ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន អាស្រ័យនូវធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ កាមុបាទាន អាស្រ័យ នូវទិដ្ឋុបាទាន ។ បណ្ឌិតគប្បីធ្វើជាចក្កៈចុះ ។ ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន អាស្រ័យ នូវធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យ នូវពួកឧបាទាន ។ ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទានក្តី ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី អាស្រ័យ នូវធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ កាមុបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យ នូវទិដ្ឋុបាទាន ។ ចក្កៈ ។ នូវធម៌ ប្រកបដោយឧបាទាន ។ សេចក្តីបំប្រួញ ។ មានការប៉ះពាល់ មានការធ្វើឲ្យផ្សេង ៗ គ្នា ដូចគ្នានឹងឧបាទានទុកៈដែរ មានបញ្ហា ៩ រូប មិនមានទេ វារៈទាំងអស់ បណ្ឌិត គប្បីឲ្យពិស្តារយ៉ាងនេះចុះ អរូបនៅដដែល ។

## បញ្ហាវារោ

[១៧៣] ឧបាទានោចេវ ឧបាទានសម្បយុត្តោ-ច ធម្មោ ឧបាទានស្សចេវ ឧបាទានសម្បយុត្តស្ស-ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ឧបាទានាចេវ-ឧបាទានសម្បយុត្តាច ហេតូ សម្បយុត្តកានំ ឧបា-ទានានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ ឧបាទានាចេវ ឧបាទានសម្បយុត្តាច ហេតូ សម្ប-យុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ ឧបាទានាចេវ ឧបាទានសម្បយុត្តាច ហេ-តូ សម្បយុត្តកានំ ខន្ធានំ ឧបាទានានញ្ច ហេតុ-ប្បច្ចយេន បច្ចយោ ។ ឧបាទានសម្បយុត្តោចេវ-នោចឧបាទានោ ធម្មោ ឧបាទានសម្បយុត្តស្សចេវ-នោចឧបាទានស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ច-យោ ឧបាទានសម្បយុត្តាចេវនោចឧបាទានា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ ឧបាទានសម្បយុត្តាចេវនោចឧបា-ទានា ហេតូ សម្បយុត្តកានំ ឧបាទានានំ ហេតុប្ប-ច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ ឧបាទានសម្ប-យុត្តាចេវនោចឧបាទានា ហេតូ សម្បយុត្តកានំ ខន្ធានំ ឧបាទានានញ្ច ហេតុប្បច្ចយេន បច្ចយោ ។

# បញ្ហាវារៈ

(១៧៣) ធម៌ ជាឧបាទានផងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានផងប្រកបដោយឧបាទាន ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ជាឧបាទានផងប្រកបដោយឧបាទាន ជាបច្ច័យ នៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកហេតុ ជាឧបាទានផងប្រកបដោយឧបាទាន ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកហេតុ ជាឧបាទានផងប្រកបដោយឧបាទាន ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង ដោយហេតុប្បច្ច័យ ។ ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកហេតុ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកហេតុ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង ដោយហេតុប្បច្ច័យ ។

ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ ច ឧបាទានសម្បយុត្តោ ចេវ នោ ច ឧបាទានោ ច ធម្មា ឧបាទានស្ស ចេវ ឧបាទានសម្បយុត្តស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ឧបាទានា ចេវ ឧបាទានសម្បយុត្តា ច ឧបាទានសម្បយុត្តា ចេវ នោ ច ឧបាទានា ច ហេតុ សម្បយុត្តកានំ ឧបាទានានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ ឧបាទានា ចេវ ឧបាទានសម្បយុត្តា ច ឧបាទានសម្បយុត្តា ចេវ នោ ច ឧបាទានា ច ហេតុ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ ឧបាទានា ចេវ ឧបាទានសម្បយុត្តា ច ឧបាទានសម្បយុត្តា ចេវ នោ ច ឧបាទានា ច ហេតុ សម្បយុត្តកានំ ខន្ធានំ ឧបាទានានញ្ច ហេតុប្បច្ចយេន បច្ចយោ ។

(១៧៤) ឧបាទានា ចេវ ឧបាទានសម្បយុត្តា ច ធម្មា ឧបាទានស្ស ចេវ ឧបាទានសម្បយុត្តស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបាទានេ អារព្ភ ឧបាទានា ឧប្បជ្ជន្តិ ។ មូលំ បុច្ឆិតព្វំ ឧបាទានេ អារព្ភ ឧបាទានសម្បយុត្តា ចេវ នោ ច ឧបាទានា ខន្ធា ឧប្បជ្ជន្តិ ។

ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទានក្តី ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ជាឧបាទានទាំងប្រកបដោយឧបាទានក្តី ពួកហេតុ ប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យ នៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកហេតុ ជាឧបាទានទាំងប្រកបដោយឧបាទានក្តី ពួកហេតុ ប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកហេតុ ជាឧបាទានទាំងប្រកបដោយឧបាទានក្តី ពួកហេតុ ប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង ដោយហេតុប្បច្ច័យ ។

( ១៧៤ ) ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយអារម្មណប្បច្ច័យ គឺ ពួកឧបាទាន កើតឡើង ព្រោះប្រារព្ធ នូវពួកឧបាទាន ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកខន្ធ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន កើតឡើង ព្រោះប្រារព្ធ នូវពួកឧបាទាន ។

មូលំ បុច្ឆិតព្វំ ឧបាទានេ អារព្ភ ឧបាទានា ច សម្ប-
យុត្តកា ច ខន្ធា ឧប្បជ្ជន្តិ ។ ឧបាទានសម្បយុត្តោ-
ចេវ នោ ច ឧបាទានោ ធម្មោ ឧបាទានសម្បយុត្តស្ស ចេវ-
នោ ច ឧបាទានស្ស ធម្មស្ស អារម្មណបច្ចយេន បច្ច-
យោ ឧបាទានសម្បយុត្តេ ចេវ នោ ច ឧបាទានេ ខន្ធេ
អារព្ភ ឧបាទានសម្បយុត្តា ចេវ នោ ច ឧបាទានា ខន្ធា
ឧប្បជ្ជន្តិ ។ តីណិបិ កាតព្វា ។ ឃដនេ តីណិបិ
កាតព្វា ។

(១៧៥) ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ-
ច ធម្មោ ឧបាទានស្ស ចេវ ឧបាទានសម្បយុត្តស្ស ច
ធម្មស្ស អធិបតិបច្ចយេន បច្ចយោ តីណិ ។ ឧបា-
ទានសម្បយុត្តោ ចេវ នោ ច ឧបាទានោ ធម្មោ ឧបាទា-
នសម្បយុត្តស្ស ចេវ នោ ច ឧបាទានស្ស ធម្មស្ស អធិ-
បតិបច្ចយេន បច្ចយោ អារម្មណាធិបតិ សហ-
ជាតាធិបតិ តីណិបិ ។ តីសុបិ ទ្វេបិ អធិបតី កា-
តព្វា ។ ឃដនាធិបតិបិ តីណិ ។

(១៧៦) ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ-
ច ធម្មោ ឧបាទានស្ស ចេវ ឧបាទានសម្ប-
យុត្តស្ស ច ធម្មស្ស អនន្តរបច្ចយេន បច្ចយោ

បណ្ឌិត គប្បីសួរ នូវមូលបទៈ ពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធ នូវពួកឧបាទាន ។ ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយអារម្មណបច្ច័យ គឺ ពួកខន្ធ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន កើតឡើង ព្រោះប្រារព្ធ នូវពួកខន្ធ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ។ បណ្ឌិត គប្បីធ្វើវារៈ ៣ យ៉ាងចុះ ។ កុងគំណដែលតគ្នា បណ្ឌិត គប្បីធ្វើវារៈ ៣ យ៉ាងទៀតចុះ ។

(១៧៥) ធម៌ ជាឧបាទានផងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានផងប្រកបដោយឧបាទាន ដោយអធិបតិបច្ច័យ គឺ មានវារៈ ៣ ។ ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយអធិបតិបច្ច័យ បានដល់អារម្មណាធិបតិ សហជាតាធិបតិ មានវារៈ ៣ ដែរ ។ អធិបតិទាំង ២ យ៉ាង បណ្ឌិត គប្បីធ្វើ កុងវារៈទាំង៣ចុះ ។ ឯឃដនាធិបតិ មានវារៈ ៣ ។

(១៧៦) ធម៌ ជាឧបាទានផងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានផងប្រកបដោយឧបាទាន ដោយអនន្តរបច្ច័យ

បុរិមា បុរិមា ឧបាទានាចេវ ឧបាទានសម្បយុត្តាច
ខន្ធា បច្ឆិមានំ បច្ឆិមានំ ឧបាទានានំ អនន្តរប្បច្ចយេន
បច្ចយោ ។ ឯវំ នវបិ បញ្ហា កាតព្វា អាវជ្ជនាបិ
វុដ្ឋានម្បិ នត្ថិ ។

( ១៧៧ ) ឧបាទានោចេវ ឧបាទានសម្បយុត្តោ-
ច ធម្មោ ឧបាទានស្សចេវ ឧបាទានសម្បយុត្តស្សច
ធម្មស្ស សមនន្តរប្បច្ចយេន បច្ចយោ នវ ។ ...
សហជាតប្បច្ចយេន បច្ចយោ នវ អញ្ញមញ្ញប្បច្ចយេន
បច្ចយោ នវ និស្សយប្បច្ចយេន បច្ចយោ នវ ។

( ១៧៨ ) ឧបាទានោចេវ ឧបាទានសម្បយុត្តោ-
ច ធម្មោ ឧបាទានស្សចេវ ឧបាទានសម្បយុត្តស្សច
ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។ បេ ។
តីណិ ។ ឧបាទានសម្បយុត្តោចេវ នោចឧបាទានោ
ធម្មោ ឧបាទានសម្បយុត្តស្សចេវ នោចឧបាទានស្ស
ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូ-
បនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ
។ បេ ។ បកតូបនិស្សយោ ឧបាទានសម្បយុត្តាចេវ-
នោចឧបាទានា ខន្ធា ឧបាទានសម្បយុត្តានញ្ចេវ នោ-
ចឧបាទានានំ ខន្ធានំ ឧបនិស្សយប្បច្ចយេន បច្ចយោ

គឺ ពួកខន្ធ ជាឧបាទានទាំងប្រកបដោយឧបាទាន មុនៗ ជាបច្ច័យ នៃពួកឧបាទាន ក្រោយៗ ដោយអនន្តរបច្ច័យ ។ បញ្ហា ៩ យ៉ាង បណ្ឌិត គប្បីធ្វើ យ៉ាងនេះចុះ អាសេវនក្តី វិបាកក្តី មិនមានទេ ។

(១៧៧) ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយសមនន្តរបច្ច័យ គឺ មានការៈ ៩ ។ ... ជាបច្ច័យ ដោយសហជាតបច្ច័យ មានការៈ ៩ ជាបច្ច័យ ដោយអញ្ញមញ្ញបច្ច័យ មានការៈ ៩ ជាបច្ច័យ ដោយនិស្សយបច្ច័យ មានការៈ ៩ ។

(១៧៨) ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយឧបនិស្សយបច្ច័យ ។ បេ ។ មានការៈ ៣ ។ ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ដែលប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយឧបនិស្សយបច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ ពួកខន្ធ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃពួកខន្ធ ដែលប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយឧបនិស្សយបច្ច័យ

តីណិ ។ ឃដនូបនិស្សយេបិ តីណិ ។ . . អាសេវ-នប្បច្ចយេន បច្ចយោ ទ្វេ ។

( ១៧៩ ) ឧបាទានសម្បយុត្តោ ចេវ នោ ច ឧបាទា-នោ ធម្មោ ឧបាទានសម្បយុត្តស្ស ចេវ នោ ច ឧបាទា-នស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ តីណិ ។ . . . អាហារប្បច្ចយេន បច្ចយោ តីណិ ឥន្ទ្រិយ-ប្បច្ចយេន បច្ចយោ តីណិ ឈានប្បច្ចយេន បច្ច-យោ តីណិ មគ្គប្បច្ចយេន បច្ចយោ ទ្វេ សម្បយុត្ត-ប្បច្ចយេន បច្ចយោ ទ្វេ អត្ថិប្បច្ចយេន បច្ចយោ ទ្វេ នត្ថិប្បច្ចយេន បច្ចយោ ទ្វេ វិគតប្បច្ចយេន បច្ចយោ ទ្វេ អវិគតប្បច្ចយេន បច្ចយោ ទ្វេ ។

( ១៨០ ) ហេតុយា ទ្វេ អារម្មណេ ទ្វេ អធិប-តិយា ទ្វេ អនន្តរេ ទ្វេ សមនន្តរេ ទ្វេ សហជាតេ ទ្វេ អញ្ញមញ្ញេ ទ្វេ និស្សយេ ទ្វេ ឧបនិស្សយេ ទ្វេ អាសេវនេ ទ្វេ កម្មេ តីណិ អាហារេ តីណិ ឥន្ទ្រិ-យេ តីណិ ឈានេ តីណិ មគ្គេ ទ្វេ សម្បយុត្តេ ទ្វេ

មានវារៈ ៣ ។ ឯកូនៃយដនូបនិស្ស័យ មានវារៈ ៣ ដែរ ។ ... ជាបច្ច័យ ដោយអាសេវនប្បច្ច័យ មានវារៈ ៩ ។

[១៧៩] ធម៌ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យ នៃធម៌ ដែលប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយកម្មប្បច្ច័យ មានវារៈ ៣ ។ ... ជាបច្ច័យ ដោយអាហារប្បច្ច័យ មានវារៈ ៣ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ជាបច្ច័យ ដោយឈានប្បច្ច័យ មានវារៈ ៣ ជាបច្ច័យ ដោយមគ្គប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយនត្ថិប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយវិគតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយអវិគតប្បច្ច័យ មានវារៈ ៩ ។

[១៨០] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩

អត្ថិយា ឆ នត្ថិយា ឆ វិគតេ ឆ អវិគតេ ឆ ។

(១៨១) ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ ច ធម្មោ ឧបាទានស្ស ចេវ ឧបាទានសម្បយុត្តស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ ច ធម្មោ ឧបាទានសម្បយុត្តស្ស ចេវ នោ ច ឧបាទានស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ ឧបាទានោ ចេវ ឧបាទានសម្បយុត្តោ ច ធម្មោ ឧបាទានស្ស ចេវ ឧបាទានសម្បយុត្តស្ស ច ឧបាទានសម្បយុត្តស្ស ចេវ នោ ច ឧបាទានស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ឯវម្បិ ឆ កាតព្វា ឯកេកស្ស មូលេ តីណិ តីណិ បញ្ហា ។

(១៨២) នហេតុយា ឆ នអារម្មណេ ឆ នអធិបតិយា ឆ សព្វត្ថ ឆ នោអវិគតេ ឆ ។

ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[១៨១] ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ដែលប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យ នៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទានផង នៃធម៌ ដែលប្រកបដោយឧបាទានតែមិនមែនជាឧបាទានផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

វារៈ ៩ បណ្ឌិត គប្បីធ្វើ យ៉ាងនេះចុះ ក្នុងមូល នៃបច្ច័យមួយៗ មានបញ្ហាបីៗ ។

[១៨២] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

(១៨៣) ហេតុប្បច្ចយា នអារម្មណេ ន៍ ... នអធិបតិយា ន៍ នអនន្តរេ ន៍ នសមនន្តរេ ន៍ នឧបនិស្សយេ ន៍ សព្វត្ថ ន៍ នមគ្គេ ន៍ នសម្បយុត្តេ ន៍ នោនត្ថិយា ន៍ នោវិគតេ ន៍ ។

(១៨៤) នហេតុប្បច្ចយា អារម្មណេ ន៍ ... អធិបតិយា ន៍ ។ អនុលោមមាតិកា កាតព្វា ។

ឧបាទានឧបាទានសម្បយុត្តទុកំ និដ្ឋិតំ ។

# ឧបាទានវិប្បយុត្តឧបាទានិយទុកំ

## បដិច្ចវារោ

(១៨៥) ឧបាទានវិប្បយុត្តំ ឧបាទានិយំ ធម្មំ បដិច្ច ឧបាទានវិប្បយុត្តោ ឧបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧបាទានវិប្បយុត្តំ ឧបាទានិយំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ ។ បេ ។ ឯកំ មហាភូតំ ...

[ ១៨៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៨៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើផងចុះ ។

ចប់ ឧបាទានឧបាទានសម្បយុត្តទុកៈ ។

# ឧបាទានវិប្បយុត្តឧបាទានិយទុកៈ

## បដិច្ចវារៈ

[ ១៨៥ ] ឧបាទានវិប្បយុត្តឧបាទានិយធម៌ ( ធម៌ដែលប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ) អាស្រ័យនូវឧបាទាន-វិប្បយុត្តឧបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបាទានវិប្បយុត្តឧបាទានិយក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ។ បេ ។ មហាភូត ១ ...

មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។ ឧបាទានវិប្បយុត្តំ អនុបាទានិយំ ធម្មំ បដិច្ច ឧបាទានវិប្បយុត្តោ អនុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧបាទានវិប្បយុត្តំ អនុបាទានិយំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ . . . ។ ឧបាទានវិប្បយុត្តំ អនុបាទានិយំ ធម្មំ បដិច្ច ឧបាទានវិប្បយុត្តោ ឧបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧបាទានវិប្បយុត្តេ អនុបាទានិយេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ ឧបាទានវិប្បយុត្តំ អនុបាទានិយំ ធម្មំ បដិច្ច ឧបាទានវិប្បយុត្តោ ឧបាទានិយោ ច ឧបាទានវិប្បយុត្តោ អនុបាទានិយោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ឧបាទានវិប្បយុត្តំ អនុបាទានិយំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ។ ឧបាទានវិប្បយុត្តំ ឧបាទានិយញ្ច ឧបាទានវិប្បយុត្តំ អនុបាទានិយញ្ច ធម្មំ បដិច្ច ឧបាទានវិប្បយុត្តោ ឧបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧបាទានវិប្បយុត្តេ អនុបាទានិយេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ។ ឧបាទានវិប្បយុត្តអនុបាទានិយធម៌ អាស្រ័យ នូវឧបាទានវិប្បយុត្តអនុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធ ១ នូវខន្ធ ២ .. ។ ឧបាទានវិប្បយុត្តឧបាទានិយធម៌ អាស្រ័យ នូវឧបាទានវិប្បយុត្តអនុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធ ។ ឧបាទានវិប្បយុត្តឧបាទានិយធម៌ក្តី ឧបាទានវិប្បយុត្តអនុបាទានិយធម៌ក្តី អាស្រ័យ នូវឧបាទានវិប្បយុត្តអនុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធ ១ ។ ឧបាទានវិប្បយុត្តឧបាទានិយធម៌ អាស្រ័យ នូវឧបាទានវិប្បយុត្តឧបាទានិយធម៌ផង នូវឧបាទានវិប្បយុត្តអនុបាទានិយធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធផង នូវពួកមហាភូតផង ។

(១៨៦) ហេតុយា បញ្ច អារម្មណេ ទ្វេ ។បេ។ អវិគតេ បញ្ច ។ ឯវំ ទុកំ ចូឡន្តរទុកេ លោកិយទុកសទិសំ និន្នានាករណំ ។

ឧបាទានវិប្បយុត្តឧបាទានិយទុកំ និដ្ឋិតំ ។

# កិលេសទុកំ

## បដិច្ចវារោ

(១៨៧) កិលេសំ ធម្មំ បដិច្ច កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា លោភំ បដិច្ច មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ លោភំ បដិច្ច មោហោ ទិដ្ឋិ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ លោភំ បដិច្ច មោហោ មានោ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ លោភំ បដិច្ច មោហោ មានោ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ លោភំ បដិច្ច មោហោ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ លោភំ បដិច្ច មោហោ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ទោសំ បដិច្ច មោហោ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ទោសំ បដិច្ច មោហោ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ វិចិកិច្ឆំ បដិច្ច មោហោ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ

[ ១៨៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ។ បេ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។ ទុកៈនេះ ដូចគ្នានឹងលោកិយទុកៈ ក្នុងចូឡន្តរទុកៈដែរ មិនមានការធ្វើឲ្យផ្សេង ៗ គ្នាទេ ។

ចប់ ឧបាទានវិប្បយុត្តឧបាទានិយទុកៈ ។

## កិលេសទុកៈ

## បដិច្ចវារៈ

[ ១៨៧ ] កិលេសធម៌ អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ទិដ្ឋិ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ មានៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវទោសៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវទោសៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវវិចិកិច្ឆា

ឧទ្ធច្ចំ បដិច្ច មោហោ អហិរិកំ អនោត្តប្បំ ។ កិ-
លេសំ ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ
ហេតុប្បច្ចយា កិលេសំ បដិច្ច សម្បយុត្តកា ខន្ធា
ចិត្តសមុដ្ឋានញ្ច រូបំ ។ កិលេសំ ធម្មំ បដិច្ច កិលេសោ
ច នោកិលេសោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា
លោភំ បដិច្ច មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អ-
នោត្តប្បំ សម្បយុត្តកា ច ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ។
ចក្កំ ។ នោកិលេសំ ធម្មំ បដិច្ច នោកិលេសោ
ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នោកិលេសំ ឯកំ
ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ
ខន្ធេ ... បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ វត្ថុំ
បដិច្ច ខន្ធា ឯកំ មហាភូតំ ... ។ នោកិលេសំ
ធម្មំ បដិច្ច កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ច-
យា នោកិលេសេ ខន្ធេ បដិច្ច កិលេសា ។ នោ-
កិលេសំ ធម្មំ បដិច្ច កិលេសោ ច នោកិលេសោ
ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នោកិលេសំ ឯកំ
ខន្ធំ បដិច្ច តយោ ខន្ធា កិលេសា ច ចិត្តសមុដ្ឋា-
នញ្ច រូបំ ទ្វេ ខន្ធេ ... កិលេសញ្ច នោកិលេ-
សញ្ច ធម្មំ បដិច្ច កិលេសោ ធម្មោ ឧប្បជ្ជតិ

មោហៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវឧទ្ធច្ចៈ ។ នោកិលេសធម៌ អាស្រ័យ នូវកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវកិលេស ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី អាស្រ័យ នូវកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មោហៈ ទិដ្ឋិ ថិនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវលោភៈ ។ ចងជាចក្កៈផងចុះ ។ នោកិលេសធម៌ អាស្រ័យ នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវនោកិលេសក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យ នូវពួកខន្ធ ពួកខន្ធ អាស្រ័យ នូវវត្ថុ មហាភូត ១ ... ។ កិលេសធម៌ អាស្រ័យ នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកកិលេស អាស្រ័យ នូវពួកនោកិលេសក្ខន្ធ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី អាស្រ័យ នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ពួកកិលេសក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវនោកិលេសក្ខន្ធ ១ នូវខន្ធ ២ ... ។ កិលេសធម៌ អាស្រ័យ នូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង

ហេតុប្បច្ចយា លោភញ្ច សម្បយុត្តកេ ច ខន្ធេ បដិច្ច មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ។ ចក្កំ ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នោ-កិលេសំ ឯកំ ខន្ធញ្ច កិលេសេ ច បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... កិលេសេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ កិ-លេសញ្ច នោកិលេសញ្ច ធម្មំ បដិច្ច កិលេសោ ច នោកិលេសោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នោកិលេសំ ឯកំ ខន្ធញ្ច លោភញ្ច បដិច្ច តយោ ខន្ធា មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... ។ ចក្កំ ។ សង្ខិត្តំ ។

(១៨៨) ហេតុយា នវ អារម្មណេ នវ អធិប-តិយា នវ អនន្តរេ នវ សមនន្តរេ នវ សព្វត្ថ នវ វិបាកេ ឯកំ អវិគតេ នវ ។

(១៨៩) កិលេសំ ធម្មំ បដិច្ច កិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆំ បដិច្ច មោហោ ឧទ្ធច្ចំ បដិច្ច មោហោ ។ នោកិលេសំ ធម្មំ បដិច្ច

ព្រោះហេតុប្បច្ច័យ គឺ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និង អនោត្តប្បៈ អាស្រ័យ នូវលោភៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ បង់ជាបក្កៈផងចុះ ។ នោកិលេសធម៌ អាស្រ័យ នូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវនោកិលេសក្ខន្ធ ១ ផង នូវពួកកិលេសផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកកិលេសផង នូវពួកមហាភូតផង ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី អាស្រ័យ នូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ និងចិត្តសមុដ្ឋានរូប អាស្រ័យ នូវនោកិលេសក្ខន្ធ១ ផង នូវលោភៈផង នូវខន្ធ ២ ... ។ បង់ជាបក្កៈផងចុះ ។ សេចក្តីបំប្រួញ ។

(១៨៨) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

(១៨៩) កិលេសធម៌ អាស្រ័យ នូវកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ អាស្រ័យ នូវវិចិកិច្ឆា មោហៈ អាស្រ័យ នូវឧទ្ធច្ចៈ ។ នោកិលេសធម៌ អាស្រ័យ

នោកិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ នោកិលេសំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . អហេតុកប្បដិសន្ធិ យាវ អសញ្ញសត្តា ។ នោកិលេសំ ធម្មំ បដិច្ច កិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បដិច្ច កិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ខន្ធេ ច វិចិកិច្ឆញ្ច បដិច្ច វិចិកិច្ឆាសហគតោ មោហោ ឧទ្ធច្ចសហគតេ ខន្ធេ ច ឧទ្ធច្ចញ្ច បដិច្ច ឧទ្ធច្ចសហាគតោ មោហោ ។

(១៩០) កិលេសំ ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា កិលេសេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ នោកិលេសំ ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា នោកិលេសេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ យាវ អសញ្ញសត្តា ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ

នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវនោកិលេសក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ . . . មានអហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ។ កិលេសធម៌ អាស្រ័យ នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ អាស្រ័យ នូវពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ។ កិលេសធម៌ អាស្រ័យ នូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលច្រឡំដោយវិចិកិច្ឆា អាស្រ័យ នូវពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆាផង នូវវិចិកិច្ឆាផង មោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ អាស្រ័យ នូវពួកខន្ធ ដែលច្រឡំដោយឧទ្ធច្ចៈផង នូវឧទ្ធច្ចៈផង ។

(១៩០) នោកិលេសធម៌ អាស្រ័យ នូវកិលេសធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកកិលេស ។ នោកិលេសធម៌ អាស្រ័យ នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកនោកិលេសក្ខន្ធ ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យ នូវពួកខន្ធ មានរហូតដល់ពួកអសញ្ញសត្វ ។ នោកិលេសធម៌ អាស្រ័យ នូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង

នអារម្មណប្បច្ចយា កិលេសេ ច សម្បយុត្តកេ ច
ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កិលេសេ ច មហា-
ភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ ... នអធិប-
តិប្បច្ចយា នអនន្តរប្បច្ចយា នសមនន្តរប្បច្ចយា ន-
អញ្ញមញ្ញប្បច្ចយា នឧបនិស្សយប្បច្ចយា ។

(១៩១) កិលេសំ ធម្មំ បដិច្ច កិលេសោ ធម្មោ
ឧប្បជ្ជតិ នបុរេជាតប្បច្ចយា អរូបេ លោភំ បដិច្ច
មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ លោភំ
បដិច្ច មោហោ ទិដ្ឋិ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ
លោភំ បដិច្ច មោហោ មានោ ថីនំ ឧទ្ធច្ចំ អហិរិកំ
អនោត្តប្បំ លោភំ បដិច្ច មោហោ មានោ ឧទ្ធច្ចំ
អហិរិកំ អនោត្តប្បំ លោភំ បដិច្ច មោហោ ថីនំ
ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ លោភំ បដិច្ច មោហោ
ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ វិចិកិច្ឆំ បដិច្ច មោហោ
ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ បដិច្ច មោហោ
អហិរិកំ អនោត្តប្បំ ។ អរូបេ ទោសមូលកំ នត្ថិ ។
កិលេសំ ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ
នបុរេជាតប្បច្ចយា អរូបេ កិលេសេ បដិច្ច សម្ប-
យុត្តកា ខន្ធា កិលេសេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកកិលេសផង នូវពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកកិលេសផង នូវពួកមហាភូតផង ។ ... ព្រោះនអធិបតិប្បច្ច័យ ព្រោះនអនន្តរប្បច្ច័យ ព្រោះនសមនន្តរប្បច្ច័យ ព្រោះនអញ្ញមញ្ញប្បច្ច័យ ព្រោះនឧបនិស្សយប្បច្ច័យ ។

(១៩១) កិលេសធម៌ អាស្រ័យ នូវកិលេសធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ក្នុងអរូប មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវលោភៈ មោហៈ ទិដ្ឋិ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវលោភៈ មោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវលោភៈ មោហៈ មានៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវវិចិកិច្ឆា មោហៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យ នូវឧទ្ធច្ចៈ ។ ក្នុងអរូប មិនមានទោសមូលទេ ។ នោកិលេសធម៌ អាស្រ័យ នូវកិលេសធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ក្នុងអរូប ពួកសម្បយុត្តកក្ខន្ធ អាស្រ័យ នូវពួកកិលេស ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកកិលេស ។

ឯវំ នវបិ បញ្ហា កាតព្វា ។ ... នបច្ឆាជាតបច្ចយា នអាសេវនបច្ចយា ។

(១៩២) កិលេសំ ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ នកម្មបច្ចយា កិលេសេ បដិច្ច សម្បយុត្តកា ចេតនា នោកិលេសំ ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ នកម្មបច្ចយា នោ-កិលេសេ ខន្ធេ បដិច្ច សម្បយុត្តកា ចេតនា ពា-ហិរំ ... អាហារសមុដ្ឋានំ ... ឧតុសមុដ្ឋានំ ... ។ បេ ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បដិច្ច នោកិលេសោ ធម្មោ ឧប្បជ្ជតិ នកម្មបច្ចយា កិ-លេសេ ច សម្បយុត្តកេ ច ខន្ធេ បដិច្ច សម្ប-យុត្តកា ចេតនា ។ ឯវំ សព្វេ បច្ចយា កាតព្វា ។

(១៩៣) នហេតុយា ចត្តារិ នអារម្មណេ តីណិ នអធិបតិយា នវ នអនន្តរេ តីណិ នសមនន្តរេ តីណិ នអញ្ញមញ្ញេ តីណិ នឧបនិស្សយេ តីណិ នបុរេជាតេ នវ នបច្ឆាជាតេ នវ នអាសេវនេ នវ នកម្មេ តីណិ នវិបាកេ នវ នអាហារេ ឯកំ

បញ្ហាទាំង ៩ យ៉ាង បណ្ឌិត គប្បីធ្វើ យ៉ាងនេះចុះ ។ ... ព្រោះនបច្ឆាជាតប្បច្ច័យ ព្រោះនអាសេវនប្បច្ច័យ ។

[ ១៩២ ] នោកិលេសធម៌ អាស្រ័យ នូវកិលេសធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺ ពួកសម្បយុត្តកចេតនា អាស្រ័យ នូវពួកកិលេស នោកិលេសធម៌ អាស្រ័យ នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺ ពួកសម្បយុត្តកចេតនា អាស្រ័យ នូវពួកនោកិលេសក្ខន្ធ ពាហិរៈ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... ។ បេ ។ នោកិលេសធម៌ អាស្រ័យ នូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺ សម្បយុត្តកចេតនា អាស្រ័យ នូវពួកកិលេសផង នូវពួកសម្បយុត្តកក្ខន្ធផង ។ បច្ច័យទាំងអស់ បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

[ ១៩៣ ] ក្នុងនហេតុប្បច្ច័យ មាន៨វារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១

នឥន្ទ្រិយេ ឯកំ នឈានេ ឯកំ នមគ្គេ ឯកំ ន-
សម្បយុត្តេ តីណិ នវិប្បយុត្តេ នវ នោនត្ថិយា តីណិ
នោវិគតេ តីណិ ។

ឯវំ ឥតរេ ទ្វេ គណនាបិ សហជាតវារោបិ
កាតព្វា ។

## បច្ចយវារោ

(១៩៤) កិលេសំ ធម្មំ បច្ចយា កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ បដិច្ចសទិសា ។ នោកិលេសំ ធម្មំ បច្ចយា នោកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នោកិលេសំ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា យាវ អជ្ឈត្តិកា មហាភូតា វត្ថុំ បច្ចយា នោកិលេសា ខន្ធា ។ នោកិលេសំ ធម្មំ បច្ចយា កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នោកិលេសេ ខន្ធេ បច្ចយា កិលេសា វត្ថុំ បច្ចយា កិលេសា ។ នោកិលេសំ ធម្មំ បច្ចយា កិលេសោ ច នោកិលេសោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នោកិលេសំ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា កិលេសា ច ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . .

ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ ២ យ៉ាង ក្រៅនេះក្តី សហជាតវារៈក្តី បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

## បច្ចយវារៈ

(១៩៤) កិលេសធម៌ ពឹងផ្អែក នូវកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោកិលេសធម៌ ពឹងផ្អែក នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែក នូវនោកិលេសក្ខន្ធ ១ រហូតដល់ពួកមហាភូតខាងក្នុង ពួកនោកិលេសក្ខន្ធ ពឹងផ្អែក នូវវត្ថុ ។ កិលេសធម៌ ពឹងផ្អែក នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកកិលេស ពឹងផ្អែក នូវពួកនោកិលេសក្ខន្ធ ពួកកិលេស ពឹងផ្អែក នូវវត្ថុ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ពឹងផ្អែក នូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ពួកកិលេសក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែក នូវនោកិលេសក្ខន្ធ ១ នូវខន្ធ ២ ...

វត្ថុំ បច្ចយា កិលេសា មហាភូតេ បច្ចយា ចិត្តសមុដ្ឋានំ រូបំ វត្ថុំ បច្ចយា កិលេសា ច សម្បយុត្តកា ច ខន្ធា ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បច្ចយា កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា លោភញ្ច សម្បយុត្តកេ ច ខន្ធេ បច្ចយា មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ។ ចក្កំ ។ លោភញ្ច វត្ថុញ្ច បច្ចយា កិលេសា ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បច្ចយា នោកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នោកិលេសំ ឯកំ ខន្ធញ្ច កិលេសេ ច បច្ចយា តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... កិលេសេ ច មហាភូតេ ច បច្ចយា ចិត្តសមុដ្ឋានំ រូបំ កិលេសេ ច វត្ថុញ្ច បច្ចយា នោកិលេសា ខន្ធា ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បច្ចយា កិលេសោ ច នោកិលេសោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នោកិលេសំ ឯកំ ខន្ធញ្ច លោភញ្ច បច្ចយា តយោ ខន្ធា មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ ... ។ ចក្កំ ។

ពួកកិលេស ពឹងផ្អែក នឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែក នឹងពួកមហាភូត ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែក នឹងវត្ថុ ។ កិលេសធម៌ ពឹងផ្អែក នឹងកិលេសធម៌ផង នឹងនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ពឹងផ្អែក នឹងលោភៈផង នឹងពួកសម្បយុត្តកក្ខន្ធផង ។ បង់ជាបក្កៈបុះ ។ ពួកកិលេស ពឹងផ្អែក នឹងលោភៈផង នឹងវត្ថុផង ។ នោកិលេសធម៌ ពឹងផ្អែក នឹងកិលេសធម៌ផង នឹងនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែក នឹងនោ-កិលេសក្ខន្ធ ១ ផង នឹងកិលេសផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែក នឹងពួកកិលេសផង នឹងពួកមហាភូតផង ពួកនោកិលេសក្ខន្ធ ពឹងផ្អែក នឹងពួកកិលេសផង នឹងវត្ថុផង ។ កិលេសធម៌ក្តី នោកិលេស-ធម៌ក្តី ពឹងផ្អែក នឹងកិលេសធម៌ផង នឹងនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែក នឹងនោកិលេស-ក្ខន្ធ ១ ផង នឹងលោភៈផង នឹងខន្ធ ២ ... ។ បង់ជាបក្កៈបុះ ។

លោកញ្ច វត្ថុញ្ច បច្ចយា មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ សម្បយុត្តកា ច ខន្ធា ។ ចក្កំ ។

អារម្មណបច្ចយេ នោកិលេសមូលេ បញ្ច វិញ្ញាណា កាតព្វា ។

(១៩៥) ហេតុយា នវ អារម្មណេ នវ អធិបតិ-យា នវ សព្វត្ថ នវ វិបាកេ ឯកំ អវិគតេ នវ ។

(១៩៦) កិលេសំ ធម្មំ បច្ចយា កិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុបច្ចយា វិចិកិច្ឆំ បច្ចយា វិចិកិច្ឆាសហគតោ មោហោ ឧទ្ធច្ចំ បច្ចយា ឧទ្ធច្ច-សហគតោ មោហោ ។ នោកិលេសំ ធម្មំ បច្ចយា នោកិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុបច្ចយា អសញ្ញសត្តា ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញា-ណំ កាយាយតនំ ... វត្ថុំ បច្ចយា អហេតុកា នោកិលេសា ខន្ធា ។ នោកិលេសំ ធម្មំ បច្ចយា កិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុបច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ ច វត្ថុញ្ច បច្ចយា វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោ-ហោ ។ កិលេសញ្ច នោកិលេសញ្ច ធម្មំ បច្ចយា កិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុបច្ចយា

មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែក នឹងលោភៈផង នឹងវត្ថុផង ។ បង់ជាបក្កៈចុះ ។

បញ្ចវិញ្ញាណ ក្នុងនោកិលេសមូល បណ្ឌិត គប្បីធ្វើ ក្នុងអារម្មណប្បច្ច័យចុះ ។

(១៩៥) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

(១៩៦) កិលេសធម៌ ពឹងផ្អែក នឹងកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ពឹងផ្អែក នឹងវិចិកិច្ឆា មោហៈ ដែលប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែក នឹងឧទ្ធច្ចៈ ។ នោកិលេសធម៌ ពឹងផ្អែក នឹងនោកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ កាយា-យតនៈ ពឹងផ្អែក នឹងចក្ខាយតនៈ... ពួកនោកិលេសក្ខន្ធ ជាអហេតុកៈ ពឹងផ្អែក នឹងវត្ថុ ។ កិលេសធម៌ ពឹងផ្អែក នឹងនោកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែក នឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ កិលេសធម៌ ពឹងផ្អែក នឹងកិលេស-ធម៌ផង នឹងនោកិលេសធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ

វិចិកិច្ឆញ្ច សម្បយុត្តកេ ច ខន្ធេ វត្ថុញ្ច បច្ចយា វិចិកិច្ឆាសហគតោ មោហោ ឧទ្ធច្ចញ្ច សម្បយុត្តកេ ច ខន្ធេ វត្ថុញ្ច បច្ចយា ឧទ្ធច្ចសហគតោ មោហោ ។ សង្ខិត្តំ ។

(១៩៧) នហេតុយា ចត្តារិ នអារម្មណេ តីណិ នអធិបតិយា នវ ។ បេ ។ នកម្មេ តីណិ នវិបាកេ នវ នអាហារេ ឯកំ នោវិគតេ តីណិ ។

ឯវំ ឥតរេ ទ្វេ គណនាបិ និស្សយវារេបិ កាតព្វា ។

## សំសដ្ឋវារោ

(១៩៨) កិលេសំ ធម្មំ សំសដ្ឋោ កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា លោភំ សំសដ្ឋោ មោហោ ទិដ្ឋិ ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ។ ចក្កំ ។ ឯវំ នវ បញ្ហា កាតព្វា ។

(១៩៩) ហេតុយា នវ អារម្មណេ នវ សព្វត្ថ នវ វិបាកេ ឯកំ អវិគតេ នវ ។

(២០០) កិលេសំ ធម្មំ សំសដ្ឋោ កិលេសោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា ឯវំ នហេតុប្បញ្ហា ចត្តារិ កាតព្វា ។

គឺ មោហៈ ដែលប្រទុំដោយវិចិកិច្ឆា ពឹងផ្អែក នឹងវិចិកិច្ឆាផង នឹងពួកសម្បយុត្តកក្ខន្ធផង នឹងវត្ថុផង មោហៈ ដែលប្រទុំដោយឧទ្ធច្ចៈ ពឹងផ្អែក នឹងឧទ្ធច្ចៈផង នឹងពួកសម្បយុត្តកក្ខន្ធផង នឹងវត្ថុផង ។ សេចក្តីបំប្រួញ ។

(១៩៧) ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។ បេ ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ឯការរាប់ ២ យ៉ាង ក្រៅពីនេះក្តី និស្សយវារៈក្តី បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

(១៩៨) កិលេសធម៌ ប្រទុំ នឹងកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ប្រទុំ នឹងលោភៈ ។ ចងជាចក្កៈចុះ ។ បញ្ហាទាំង ៩ បណ្ឌិត គប្បីធ្វើ យ៉ាងនេះចុះ ។

(១៩៩) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

(២០០) កិលេសធម៌ ប្រទុំ នឹងកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ នហេតុបញ្ហា ៤ យ៉ាង បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

(២០១) នហេតុយា ចត្តារិ នអធិបតិយា នវ នបុរេជាតេ នវ នបច្ឆាជាតេ នវ នអាសេវនេ នវ នកម្មេ តីណិ នវិបាកេ នវ នឈានេ ឯកំ នមគ្គេ ឯកំ នវិប្បយុត្តេ នវ ។

ឯវំ ឥតរេ ទ្វេ គណនាបិ សម្បយុត្តវារេបិ កាតព្វា ។

## បញ្ហាវារោ

(២០២) កិលេសោ ធម្មោ កិលេសស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ កិលេសា ហេតូ សម្បយុត្តកានំ កិលេសានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ កិលេសា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។ មូលំ បុច្ឆិតព្វំ កិលេសា ហេតូ សម្បយុត្តកានំ ខន្ធានំ កិលេសានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ នោកិលេសស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ នោកិលេសា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិ ។

[ ២០១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

ការរាប់ពីរយ៉ាង ក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ២០២ ] កិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ ដោយហេតុប្បច្ច័យ គឺ ពួកកិលេសហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកកិលេស ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកកិលេសហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកកិលេសហេតុ ជាបច្ច័យ នៃសម្បយុត្តកក្ខន្ធផង នៃពួកកិលេសផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យ នៃនោកិលេសធម៌ ដោយហេតុប្បច្ច័យ គឺ ពួកនោកិលេសហេតុ ជាបច្ច័យ គឺជាបដិសន្ធិ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

(២០៣) កិលេសោ ធម្មោ កិលេសស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ កិលេសេ អារព្ភ កិលេសា ឧប្បជ្ជន្តិ ។ មូលំ បុច្ឆិតព្វំ កិលេសេ អារព្ភ នោកិលេសា ឧប្បជ្ជន្តិ ។ មូលំ បុច្ឆិតព្វំ កិលេសេ អារព្ភ កិលេសា ច សម្បយុត្តកា ច ខន្ធា ឧប្បជ្ជន្តិ ។ នោកិលេសោ ធម្មោ នោកិលេសស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ... សីលំ ... ឧបោសថកម្មំ ... បុព្វេ សុចិណ្ណានិ ... ឈានា វុដ្ឋហិត្វា ឈានំ បច្ចវេក្ខតិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ... ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចំ ... នោមនស្សំ ឧប្បជ្ជតិ អរិយា មគ្គា វុដ្ឋហិត្វា ។ បេ ។ ផលស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ចក្ខុំ ... វត្ថុំ ... នោកិលេសេ ខន្ធេ អនិច្ចតោ ។ បេ ។ នោមនស្សំ ឧប្បជ្ជតិ ទិព្វេន ចក្ខុនា រូបំ បស្សតិ ទិព្វាយ សោតធាតុយា ។ បេ ។ អនាគតំសញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ នោកិលេសោ ធម្មោ កិលេសស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ។ បេ ។ ឈានា វុដ្ឋហិត្វា

[២០៣] កិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ ដោយអារម្មណប្បច្ច័យ គឺ ពួកកិលេស កើតឡើង ព្រោះប្រារព្ធ នូវពួកកិលេស ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកនោកិលេស កើតឡើង ព្រោះប្រារព្ធ នូវពួកកិលេស ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធ នូវពួកកិលេស ។ នោកិលេសធម៌ ជាបច្ច័យ នៃនោកិលេសធម៌ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល (ឲ្យ) នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ចេញ អំពីឈាន ពិចារណា នូវឈាន ត្រេកអរ រីករាយ រាគៈ ... ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ... ទោមនស្ស កើតឡើង ព្រោះប្រារព្ធ នូវកុសលនោះ ពួកព្រះអរិយៈ ចេញ អំពីមគ្គ ។ បេ ។ ជាបច្ច័យ នៃការពិចារណា នូវផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... នូវពួកនោកិលេសក្ខន្ធ ជាមិនទៀង ។ បេ ។ ទោមនស្ស កើតឡើង បុគ្គល ឃើញ នូវរូប ដោយទិព្វចក្ខុ ដោយទិព្វសោតធាតុ ។ បេ ។ ជាបច្ច័យ នៃការពិចារណា នូវអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ នោកិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល (ឲ្យ) នូវទាន ។ បេ ។ ចេញ អំពីឈាន

ឈានំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ... ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចំ ។ បេ ។ ឈានេ បរិហីនេ វិប្បដិសារិស្ស ទោមនស្សំ ឧប្បជ្ជតិ ចក្ខុំ ... វត្ថុំ ... នោកិលេសេ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ។ បេ ។ ទោមនស្សំ ... ។ នោកិលេសោ ធម្មោ កិលេសស្ស ច នោកិលេសស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ។ បេ ។ ឈានា វុដ្ឋហិត្វា ។ បេ ។ ចក្ខុំ ... វត្ថុំ ... នោកិលេសេ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ កិលេសា ច សម្បយុត្តកា ច ខន្ធា ឧប្បជ្ជន្តិ ។ កិលេសោ ច នោកិលេសោ ច ធម្មា កិលេសស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។

(២០៤) កិលេសោ ធម្មោ កិលេសស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ កិលេសេ គរុំ កត្វា កិលេសា ឧប្បជ្ជន្តិ ។ តីណិ អារម្មណាធិបតិយេវ ។ នោកិលេសោ ធម្មោ នោកិលេសស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។

ត្រេកអរ រីករាយ នឹងឈាន រាគៈ ... ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចៈ ព្រោះប្រារព្ធ នូវកុសលនោះ ៗ បេ ៗ ទោមនស្ស របស់បុគ្គលអ្នកមានសេចក្តីស្តាយក្រោយ ព្រោះសាបសូន្យឈាន កើតឡើង នឹងចក្ខុ ... នឹងវត្ថុ ... បុគ្គល ត្រេកអរ រីករាយ នឹងពួកនោ-កិលេសក្ខន្ធ រាគៈ ប្រារព្ធ នូវធម៌នោះ ៗ បេ ៗ ទោមនស្ស ... ៗ នោកិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ផង នៃនោកិលេសធម៌ផង ដោយអារម្មណប្បច្ច័យ គឺ បុគ្គល (ឲ្យ) នូវទាន ៗ បេ ៗ ចេញអំពីឈាន ៗ បេ ៗ នឹងចក្ខុ ... នឹងវត្ថុ ... បុគ្គល ត្រេកអរ រីករាយ នឹងពួកនោកិលេសក្ខន្ធ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធ នូវខន្ធនោះ ៗ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ជាបច្ច័យ នៃកិលេសធម៌ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ៗ

(២០៤) កិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺ ពួកកិលេស កើតឡើង ព្រោះធ្វើ នូវពួកកិលេស ឲ្យជាទីគោរព ៗ មានវារៈ ៣ នៅជាអារម្មណាធិបតិដដែល ៗ នោកិលេសធម៌ ជាបច្ច័យ នៃនោកិលេសធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ៗ

អារម្មណាធិបតិ ទានំ . . . សីលំ . . . ឧបោសថកម្មំ កត្វា តំ គរុំ កត្វា បច្ចវេក្ខតិ អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ បុព្វេ . . . ឈានា . . . អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ គរុំ កត្វា ។ បេ ។ ផលស្ស អធិបតិប្បច្ចយេន បច្ចយោ ចក្ខុំ . . . វត្ថុំ . . . នោកិលេសេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ . . . ។ សហជាតាធិបតិ នោកិលេសា អធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ កិលេសស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ ទានំ ។ បេ ។ ឈានំ . . . ចក្ខុំ . . . វត្ថុំ . . . នោកិលេសេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ . . . ។ សហជាតាធិបតិ នោកិលេសា អធិបតិ សម្បយុត្តកានំ កិលេសានំ អធិបតិប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ កិលេសស្ស ច នោកិលេសស្ស ច ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ

អារម្មណាធិបតិ គឺ បុគ្គល (ឲ្យ) នូវទាន ... នូវសីល ... ធ្វើ នូវឧបោសថកម្ម ធ្វើ នូវកុសលកម្មនោះ ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈ កើតឡើង ទិដ្ឋិ កើតឡើង ព្រោះធ្វើ នូវកុសលនោះ ឲ្យជាទីគោរព ក្នុងកាលមុន ... អំពីឈាន ... ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយធ្វើ នូវមគ្គ ឲ្យជាទីគោរព ។ បេ ។ ជាបច្ច័យ នៃផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... បុគ្គល ធ្វើនូវពួកនោកិលេសក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើ នូវកុសលនោះ ឲ្យទីគោរព ទិដ្ឋិ ... ។ ឯសហជាតាធិបតិ គឺ នោកិលេសាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល (ឲ្យ) នូវទាន ។ បេ ។ នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គល ធ្វើ នូវពួកនោកិលេសក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើ នូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិ ... ។ ឯសហជាតាធិបតិ គឺ នោកិលេសាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកកិលេស ដោយអធិបតិប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ផង នៃនោកិលេសធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ

សហជាតាធិបតិ ។ អារម្មណាធិបតិ ទានំ ។ បេ ។ ឈានំ ... ចក្ខុំ ... វត្ថុំ ... នោកិលេសេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា កិលេសា ច សម្បយុត្តកា ច ខន្ធា ឧប្បជ្ជន្តិ ។ សហជាតាធិបតិ នោកិលេសា អធិបតិ សម្បយុត្តកានំ ខន្ធានំ កិលេសានញ្ច ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ កិលេសោ ច នោកិលេសោ ច ធម្មា កិលេសស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ តីណិ អារម្មណាធិបតិយេវ ។

(២០៥) កិលេសោ ធម្មោ កិលេសស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ បុរិមា បុរិមា កិលេសា បច្ឆិមានំ បច្ឆិមានំ កិលេសានំ អនន្តរប្បច្ចយេន បច្ចយោ ។ មូលំ បុរិមា បុរិមា កិលេសា បច្ឆិមានំ បច្ឆិមានំ នោកិលេសានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ កិលេសា វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។ មូលំ បុរិមា បុរិមា កិលេសា បច្ឆិមានំ បច្ឆិមានំ កិលេសានំ សម្បយុត្តកានញ្ច ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ នោកិលេសស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ

និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល (ឲ្យ) នូវទាន ។បេ។ នូវឈាន ... នូវបក្ខ ... នូវវត្ត ... បុគ្គល ធ្វើ នូវពួកនោកិលេសក្ខន្ធ ឲ្យជាទីគោរព ត្រេកអរ រីករាយ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើ នូវធម៌នោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺ នោកិលេសាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកិលេសផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ជាបច្ច័យ នៃកិលេសធម៌ ដោយអធិបតិប្បច្ច័យ គឺ មានវារៈ ៣ នៅជាអារម្មណាធិបតិដដែល ។

(២០៥) កិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ ដោយអនន្តរប្បច្ច័យ គឺ ពួកកិលេស មុន ៗ ជាបច្ច័យ នៃពួកកិលេស ក្រោយៗ ដោយអនន្តរប្បច្ច័យ ។ គប្បីសួរ នូវមូលផងចុះ ពួកកិលេស មុន ៗ ជាបច្ច័យ នៃពួកនោកិលេសក្ខន្ធ ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ពួកកិលេស ជាបច្ច័យ នៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ គប្បីសួរ នូវមូលផងចុះ ពួកកិលេស មុន ៗ ជាបច្ច័យ នៃពួកកិលេសផង នៃពួកសម្បយុត្តកក្ខន្ធផង ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យ នៃនោកិលេសធម៌ ដោយអនន្តរប្បច្ច័យ

បុរិមា បុរិមា នោកិលេសា ខន្ធា បច្ឆិមានំ បច្ឆិមានំ នោកិលេសានំ អនន្តរប្បច្ចយេន បច្ចយោ ។ បេ ។ ផលសមាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។ មូលំ បុរិមា បុរិមា នោកិលេសា ខន្ធា បច្ឆិមានំ បច្ឆិមានំ កិលេសានំ អនន្តរប្បច្ចយេន បច្ចយោ អាវជ្ជនា កិលេសានំ អនន្តរប្បច្ចយេន បច្ចយោ ។ មូលំ បុរិមា បុរិមា នោកិលេសា ខន្ធា បច្ឆិមានំ បច្ឆិមានំ កិលេសានំ សម្បយុត្តកានញ្ច ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ អាវជ្ជនា កិលេសានំ សម្បយុត្តកានញ្ច ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។ កិលេសា ច នោកិលេសា ច ធម្មា កិលេសស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ បុរិមា បុរិមា កិលេសា ច សម្បយុត្តកា ច ខន្ធា បច្ឆិមានំ បច្ឆិមានំ កិលេសានំ អនន្តរប្បច្ចយេន បច្ចយោ ។ មូលំ បុរិមា បុរិមា កិលេសា ច សម្បយុត្តកា ច ខន្ធា បច្ឆិមានំ បច្ឆិមានំ នោកិលេសានំ អនន្តរប្បច្ចយេន បច្ចយោ កិលេសា ច សម្បយុត្តកា ច ខន្ធា វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។ មូលំ បុរិមា បុរិមា កិលេសា ច សម្បយុត្តកា ច ខន្ធា

គឺ ពួកនោកិលេសក្ខន្ធ មុន ៗ ជាបច្ច័យ នៃពួកនោកិលេស ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។ បេ ។ ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ គប្បីសួរ នូវមូលផង៏ចុះ ពួកនោកិលេសក្ខន្ធ មុន ៗ ជាបច្ច័យ នៃពួកកិលេស ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យ នៃពួកកិលេស ដោយអនន្តរប្បច្ច័យ ។ គប្បីសួរ នូវមូលផង៏ចុះ ពួកនោកិលេសក្ខន្ធ មុន ៗ ជាបច្ច័យ នៃពួកកិលេសផង៏ នៃពួកសម្បយុត្តកក្ខន្ធផង៏ ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យ នៃពួកកិលេសផង៏ នៃពួកសម្បយុត្តកក្ខន្ធផង៏ ដោយអនន្តរប្បច្ច័យ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ជាបច្ច័យ នៃពួកកិលេសធម៌ ដោយអនន្តរប្បច្ច័យ គឺ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី មុន ៗ ជាបច្ច័យ នៃពួកកិលេស ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។ គប្បីសួរ នូវមូលផង៏ចុះ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី មុន ៗ ជាបច្ច័យ នៃពួកនោកិលេស ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យ នៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ គប្បីសួរ នូវមូលផង៏ចុះ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី មុន ៗ

បច្ឆិមានំ បច្ឆិមានំ កិលេសានំ សម្បយុត្តកានញ្ច ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។ ... សមនន្តរប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ អញ្ញមញ្ញប្បច្ចយេន បច្ចយោ និស្សយប្បច្ចយេន បច្ចយោ ។

(២០៦) កិលេសោ ធម្មោ កិលេសស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ កិលេសា កិលេសានំ ... តីណិ ។ នោកិលេសោ ធម្មោ នោកិលេសស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ សទ្ធំ ឧបនិស្សាយ ទានំ ទេតិ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ សីលំ ។ បេ ។ បញ្ញំ ... រាគំ ទោសំ មោហំ មានំ ទិដ្ឋឹ បត្ថនំ កាយិកំ សុខំ ... សេនាសនំ ឧបនិស្សាយ ទានំ ទេតិ ។ បេ ។ សង្ឃំ ភិន្ទតិ សទ្ធា ។ បេ ។ សេនាសនំ សទ្ធាយ ។ បេ ។ ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ កិលេសស្ស ធម្មស្ស

ជាបច្ច័យ នៃពួកកិលេសផង នៃពួកសម្បយុត្តកក្ខន្ធផង ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ ។

[ ២០៦ ] កិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ ពួកកិលេស នៃពួកកិលេស ... មាន៣ៈ ៣ ។ នោកិលេសធម៌ ជាបច្ច័យ នៃនោកិលេសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ហើយឲ្យនូវទាន តម្កើង នូវមានះ ប្រកាន់ នូវទិដ្ឋិ នូវសីល ។ បេ ។ នូវបញ្ញា ... នូវរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ សេចក្តីប្រាថ្នា និងកាយិកសុខ ... បុគ្គល អាស្រ័យ នូវសេនាសនៈ ហើយឲ្យ នូវទាន ។ បេ ។ បំបែក នូវសង្ឃ សទ្ធា ។ បេ ។ សេនាសនៈ ជាបច្ច័យ នៃសទ្ធា ។ បេ ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យ នៃកិលេសធម៌

ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ សទ្ធំ ឧបនិស្សាយ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ សីលំ ។ បេ ។ សេនាសនំ ឧបនិស្សាយ បាណំ ហនតិ ។ បេ ។ សង្ឃំ ភិន្ទតិ សទ្ធា ។ បេ ។ សេនាសនំ កិលេសានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ កិលេសស្ស ច នោកិលេសស្ស ច ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ សទ្ធំ ឧបនិស្សាយ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ សីលំ ។ បេ ។ សេនាសនំ ឧបនិស្សាយ បាណំ ហនតិ ។ បេ ។ សង្ឃំ ភិន្ទតិ សទ្ធា ។ បេ ។ សេនាសនំ កិលេសានំ សម្បយុត្តកានញ្ច ខន្ធានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ កិលេសោ ច នោកិលេសោ ច ធម្មា កិលេសស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ តីណិ ។

( ២០៧ ) នោកិលេសោ ធម្មោ នោកិលេសស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ ។ អារម្មណបុរេជាតំ

ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិ-ស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល អា-ស្រ័យ នូវសទ្ធា ហើយតម្កើង នូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ។ បេ ។ បុគ្គល អាស្រ័យ នូវសេនាសនៈ ហើយសម្លាប់ នូវសត្វ ។ បេ ។ បំបែក នូវសង្ឃ សទ្ធា ។ បេ ។ សេនាសនៈ ជាបច្ច័យ នៃពួកកិលេស ដោយឧបនិស្សយប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យ នៃកិលេស-ធម៌ផង នៃនោកិលេសធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯប-កតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ហើយតម្កើង នូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ។ បេ ។ បុគ្គល អាស្រ័យ នូវសេនាសនៈ ហើយសម្លាប់ នូវសត្វ ។ បេ ។ បំបែក នូវសង្ឃ សទ្ធា ។ បេ ។ សេនាសនៈ ជាបច្ច័យ នៃពួកកិលេសផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ជា បច្ច័យ នៃកិលេសធម៌ ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។

(២០៧) នោកិលេសធម៌ ជាបច្ច័យ នៃនោកិលេសធម៌ ដោយបុរេជា-តប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត

ចក្ខុំ ... វត្ថុំ អនិច្ចតោ ។ បេ ។ ទោមនស្សំ ឧប្បជ្ជតិ ទិព្វេន ចក្ខុនា រូបំ បស្សតិ ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ រូបាយតនំ ចក្ខុវិញ្ញាណស្ស ផោដ្ឋព្វាយតនំ ... ។ វត្ថុបុរេជាតំ វត្ថុ នោកិលេសានំ ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ កិលេសស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ ។ អារម្មណបុរេជាតំ ចក្ខុ ... វត្ថុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ។ បេ ។ ទោមនស្សំ ឧប្បជ្ជតិ ។ វត្ថុបុរេជាតំ វត្ថុ កិលេសានំ បុរេជាតប្បច្ចយេន បច្ចយោ ។ នោកិលេសោ ធម្មោ កិលេសស្ស ច នោកិលេសស្ស ច ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ ។ អារម្មណបុរេជាតំ ចក្ខុំ ... វត្ថុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ កិលេសា ច សម្បយុត្តកា ច ខន្ធា ឧប្បជ្ជន្តិ ។ វត្ថុបុរេជាតំ វត្ថុ កិលេសានំ សម្បយុត្តកានញ្ច ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ ។

